ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ៤៧ អយក.សណន

# សេចក្តីណែនាំ
# ដំណើរការគ្រឹះស្ថានបឋមសិក្សា និងមត្តេយ្យសិក្សាសាធារណៈ
# ឆ្នាំសិក្សា ២០១៦ - ២០១៧

ឆ្នាំសិក្សា២០១៦-២០១៧នេះ ដំណើរការនៃការអប់រំបឋមសិក្សា នៅតែផ្តោតយ៉ាងសំខាន់លើការអនុវត្តកម្មវិធីសាលាកុមារមេត្រី ឯការអប់រំមត្តេយ្យសិក្សានៅតែផ្តោតលើការអនុវត្តកម្មវិធីតាមស្តង់ដាការសិក្សា ដើម្បីធានាបាននូវការអប់រំមួយប្រកបដោយសមធម៌ និងគុណភាពក៏ដូចជាការធ្វើឱ្យសម្រេចនូវគោលដៅ និងចំណុចដៅនានានៃកំណែទម្រង់វិស័យអប់រំ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ។ក្នុងស្មារតីនេះ ក្រសួងអប់រំ យុវជន និងកីឡា សូមធ្វើការណែនាំដល់គ្រប់រាជធានី ខេត្ត នូវការងារមួយចំនួនសម្រាប់ឆ្នាំសិក្សា២០១៦-២០១៧ ដូចខាងក្រោម ៖

## I- រយៈពេលនៃឆ្នាំសិក្សា

ឆ្នាំសិក្សាថ្មី២០១៦-២០១៧ ត្រូវចាប់ផ្តើមពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៦ និងបញ្ចប់នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៧ ដោយកំណត់យក ៖

១.ថ្ងៃបើកបវេសនកាល ប្រព្រឹត្តទៅនៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ ២០១៦

២.ថ្ងៃវិស្សមកាលប្រព្រឹត្តទៅ ២ ដង គឺ ៖

ក.វិស្សមកាលតូច ៖ ពីថ្ងៃទី ០៦ ដល់ថ្ងៃទី១៩ ខែមេសា ឆ្នាំ ២០១៧

ខ.មហាវិស្សមកាល ៖ ពីថ្ងៃទី ០១ ខែកញ្ញា ដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ ២០១៧ ។

## II-ការរៀបចំមុនដំណើរការសិក្សា

### ១.មុនបវេសនកាល

សាលាបឋមសិក្សានិងមត្តេយ្យសិក្សាសាធារណៈត្រូវរៀបចំដំណើរការរបស់ខ្លួនចំនួន១៥ថ្ងៃមុនថ្ងៃបើកបវេសនកាល និងត្រូវចាត់ចែងការងារដូចខាងក្រោម ៖

១.១. ការប្រជុំគ្រូ និងសហគមន៍ ដើម្បី ៖

- ធ្វើបច្ចុប្បន្នភាពក្រុមបណ្តាញខ្នងផ្ទះនិងកែលម្អផែនទីខ្នងផ្ទះឬធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិក្នុងផែនទីខ្នងផ្ទះឡើងវិញរបស់សាលារៀន ។



6

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១០ ១៨៧ /២១៧ ២៥៣ /៤២៦ ៩៥១ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០/ ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ : www.moeys.gov.kh

- កសាងផែនការអភិវឌ្ឍសាលារៀនសម្រាប់ឆ្នាំសិក្សាថ្មី ២០១៦-២០១៧ ឱ្យស្របទៅនឹងសមាសភាគទាំង៦ នៃកម្មវិធីសាលាកុមារមេត្រី ពិសេសសកម្មភាពសំខាន់ៗក្នុងឯកសារគាំទ្រការអនុវត្តដែលបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការក៏ដូចជាថវិកាកម្មវិធី ( PB ) និងថវិកាជំនួយដើម្បីកែលម្អសាលារៀន ( SIG ) និងថវិកាពីប្រភពផ្សេងៗរបស់សាលារៀន។
- បែងចែកភារកិច្ចទទួលខុសត្រូវក្នុងការផ្សព្វផ្សាយនិងធ្វើយុទ្ធនាការប្រមូលកុមារចាប់ពីអាយុ៣ទៅក្រោម៦ឆ្នាំ (សម្រាប់មត្តេយ្យសិក្សា) និងចាប់ពីអាយុ៦ឆ្នាំ ឬយ៉ាងតិច៧០ខែ ( សម្រាប់បឋមសិក្សា ) ឱ្យចូលរៀនដោយចងបដា ពាក្យស្លោក នៅតាមទីប្រជុំជនធ្វើការអំពាវនាវដល់មាតាបិតាឬអាណាព្យាបាល សិស្ស ឱ្យនាំកូនដល់អាយុមកចុះឈ្មោះចូលរៀនគ្រប់ៗគ្នា ។
- ទទួលកុមារថ្មីនៅមត្តេយ្យសិក្សានិងកុមារចូលរៀនថ្មីថ្នាក់ទី១ក្នុងសាលាបឋមសិក្សានិងធ្វើការបែងចែកសិស្សតាមកម្រិតថ្នាក់ឱ្យបានសមស្រប។
- ជំរុញការបង្រៀនសរសេរតាមអាន តែងសេចក្តី និងអក្សរផ្ចង់តាមស្មារតីលិខិតលេខ ១៩អយក.សណន ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១១។
- ពង្រឹងការប្រើប្រាស់សៀវភៅសិក្សាគោលភាសាខ្មែរ « អាន សរសេរ » ថ្នាក់ទី១ ទី២ និង ទី៣ និងការបង្រៀនគណិតវិទ្យាថ្នាក់ដំបូង ។
- ផ្សព្វផ្សាយ និងពង្រឹងការប្រើប្រាស់សៀវភៅភាសាអង់គ្លេសចាប់ពីថ្នាក់ទី៤ដល់ថ្នាក់ទី៦
- ផ្សព្វផ្សាយសេចក្តីណែនាំនិងសារាចរនានាដែលពាក់ព័ន្ធនិងកំពុងស្ថិតនៅជាធរមានពិសេសច្បាប់ស្តីពីការអប់រំក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀនប្រកាសស្តីពីបទបញ្ជាផ្ទៃក្នុងសម្រាប់គ្រឹះស្ថានបឋមសិក្សានិងមត្តេយ្យសិក្សាសារាចរណែនាំស្តីពី ការអនុវត្តប្រកាសបទបញ្ជាផ្ទៃក្នុសម្រាប់គ្រឹះស្ថានបឋមសិក្សាសាធារណៈ និងមត្តេយ្យសិក្សាសាធារណៈ។
- បែងចែកគ្រូទទួលបន្ទុកថ្នាក់និងរៀបចំប្រធាន អនុប្រធានក្រុមបច្ចេកទេសតាមកម្រិតថ្នាក់
- ជ្រើសរើសសមាសភាពគណៈកម្មការទ្រទ្រង់សាលាបឋមសិក្សាថ្មី ស្របតាមសេចក្តីណែនាំលេខ ៣០ អយក.សណន.ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១២
- រៀបចំជួសជុលបន្ទប់រៀន សង្ហារិម តុ កៅអី ក្តារខៀន ទ្វារ បង្អួច បង្គន់អនាម័យ ខ្លោងទ្វារ ស្លាកសាលារៀន កន្លែងលាងសម្អាតដៃ និងបរិក្ខារនានាដើម្បីធានាបានបរិស្ថានសិក្សារបស់សិស្សប្រកបដោយជាសុកភាព
- ជំរុញការយកចិត្តទុកដាក់ដល់ការថែរក្សាបរិស្ថានសាលារៀន ក្នុងនិងក្រៅថ្នាក់រៀន ដោយផ្តោតលើការប្រមូលទុកដាក់និងដុតសំរាម ដើម្បីធានាដល់សុខុមាលភាពនិងបរិស្ថានសាលាកុមារមេត្រី
- ចំពោះការរៀបចំអនាម័យនិងបរិស្ថានសិក្សានេះត្រូវរៀបចំជាប់ជាប្រចាំដោយៈ

1. ចាត់តាំងនាយករង-នាយិការងម្នាក់ ទទួលបន្ទុកដោយរៀបចំជាកាលវិភាគសិស្សសម្អាតតាមថ្នាក់ សួនច្បារមុខថ្នាក់រៀន បោសសម្អាត ជូតទ្វារបង្អួច ធ្វើពលកម្មដោយប្រើប្រាស់យន្តការ



២

ក្រុមប្រឹក្សាកុមារ

2. ចាត់តាំងក្រុមប្រឹក្សាកុមាររៀបចំទិវាពលកម្មបោសសម្អាត ទីធ្លាសាលារៀនជុំវិញសាលារៀន និងទីសាធារណៈ
3. សាលារៀនត្រូវមានសម្ភារៈសម្រាប់សិស្សបោសសម្អាត និងធ្វើពលកម្ម
4. មានការចុះពិនិត្យសណ្តាប់ធ្នាប់អនាម័យនិងបរិស្ថានសិក្សាជាប់ជាប្រចាំ ពិសេសសំរាម គឺធានាថាក្នុងសាលារៀនស្អាតជានិច្ច។

- លើកគម្រោងប្រើប្រាស់ថវិកាកម្មវិធី (PB) ឱ្យបានសមស្របតាមតម្រូវការ តាមជំពូក គណនី និងអនុគណនី តាមមាតិកាថវិកាថ្មី ផ្អែកតាមប្រកាសអន្តរក្រសួងលេខ ៥០៨ សហវ.ប្រក ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ២០១៣
- ផ្សព្វផ្សាយការអនុវត្តកម្មវិធីជំនួយដើម្បីកែលម្អសាលារៀន (SIG) សម្រាប់ឆ្នាំសិក្សាថ្មី ។

១.២.ការប្រជុំសិស្សានុសិស្សនៅបឋមសិក្សា ( ៥ថ្ងៃមុនបើកបវេសនកាល ) ដើម្បី ៖

- សម្អាតបរិស្ថានសាលារៀន (បន្ទប់រៀន បណ្ណាល័យ បង្គន់អនាម័យ ទីធ្លា ការញែកសំរាម ដុតទុកដាក់ឱ្យបានត្រឹមត្រូវ...)។
- ជួសជុលសៀវភៅសិក្សាគោលនិងធ្វើផែនការបែងចែកដល់សិស្សឱ្យបានទាន់ពេលវេលា
- រៀបចំបោះឆ្នោតជ្រើសរើសគណៈកម្មាធិការប្រតិបត្តិក្រុមប្រឹក្សាកុមារ
- ចាត់ចែង និងប្រើប្រាស់ថវិកាឱ្យមានកម្លាភាព ប្រសិទ្ធភាព ជាពិសេសសាលាបឋមសិក្សាដែលមានសាលាឬថ្នាក់មត្តេយ្យសិក្សា។

១.៣.ការប្រជុំក្រុមបច្ចេកទេសនិងគ្រូកម្រិតថ្នាក់(មុនថ្ងៃចូលរៀន៥ថ្ងៃ)ដើម្បីរៀបចំនិងបែងចែកកាលវិភាគសិក្សា កម្មវិធីសិក្សា បទបញ្ជាផ្ទៃក្នុង បញ្ជីសារពើភ័ណ្ឌ។ល។ឱ្យយកទៅបិទតាមថ្នាក់មុនពេលដំណើរការសិក្សា។រៀបចំវិញ្ញាសាតេស្តដើមឆ្នាំតាមកម្រិតថ្នាក់ចំពោះសាលារៀននៅមានសិស្សធ្លាក់ពីការធ្វើតេស្តចុងឆ្នាំសិក្សា។

## ២-ការប្រារព្ធពិធីបើកបវេសនកាល

### ២.១.សម្រាប់បឋមសិក្សា

នៅថ្ងៃបើកបវេសនកាល ( ថ្ងៃទី០១ វិច្ឆិកា ) គ្រប់សាលារៀនត្រូវរៀបចំចងបដាពាក្យស្លោកអបអរសាទរ បវេសនកាលឱ្យបានមុនថ្ងៃប្រារព្ធពិធីដោយអញ្ជើញថ្នាក់ដឹកនាំឬ មន្ត្រីក្រសួងអប់រំយុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យ អយក ស្រុក ខណ្ឌ អាជ្ញាធរដែនដី តំណាងសហគមន៍មាតាបិតាឬអ្នកអាណាព្យាបាលសិស្សចូលរួមឱ្យបានច្រើនតាមលទ្ធភាពជាទ្រង់ទ្រាយ ធំ មធ្យម ឬតូច ដោយធ្វើព្យុហយាត្រាតាមដងផ្លូវ និងបិទផ្សាយ បដា ពាក្យស្លោកទាក់ទងនឹងការចូលរៀនដោយឥតបង់ថ្លៃតាមសេចក្តីណែនាំបវេសនកាលឆ្នាំសិក្សានាពេលកន្លងមក ។

### ២.២.មត្តេយ្យសិក្សា

ថ្នាក់មត្តេយ្យសិក្សាដែលនៅក្នុងបឋមសិក្សាត្រូវ ចូលរួមបើកបវេសនកាលជាមួយសាលារៀនបឋមសិក្សា រីឯមត្តេយ្យសិក្សាដែលនៅដាច់ដោយឡែក និងថ្នាក់មត្តេយ្យសិក្សាសហគមន៍ គប្បីរៀបចំកន្លែង និងកម្មវិធីឱ្យបានសមស្របដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យ.អយក.ស្រុក.ខណ្ឌ អាជ្ញាធរដែនដី គណៈកម្មការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំសង្កាត់ សហគមន៍ ព្រះសង្ឃ មាតាបិតាឬអ្នកអាណាព្យាបាលសិស្ស។

## III-ការងារសំខាន់ៗសម្រាប់ទ្រទ្រង់ដំណើរការសិក្សា

ក្នុងឆ្នាំសិក្សាសាលារៀនទាំងអស់ត្រូវធានារយៈពេលសិក្សាឱ្យបានពេញលេញគឺ ៣៨សប្តាហ៍ ដោយមួយសប្តាហ៍ចំនួន២៥-២៧ម៉ោង ដោយអនុវត្តទៅតាមសេចក្តីណែនាំស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំតាមលិខិតលេខ៣៣ អយក.សណន.ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ សម្រាប់រាជធានី ខេត្តសាកល្បងទាំង៤ (រាជធានីភ្នំពេញ កណ្តាល មណ្ឌលគិរី ស្វាយរៀង)និងខេត្តដទៃទៀតអនុវត្តតាមនិយាមចាស់សិន ដើម្បីធានាបាននូវគុណភាពនិងប្រសិទ្ធភាពនៃដំណើរការការសិក្សា។

មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ កម្រងសាលារៀន គ្រប់សាលារៀនត្រូវយកចិត្តទុកដាក់លើការងារសំខាន់ៗតាមតួនាទីនិងភារកិច្ចរបស់ខ្លួនដូចខាងក្រោម ៖

### ១.ការគ្រប់គ្រងស្ថិតិ និងឯកសារនានា

- ចាត់តាំងមន្ត្រីទទួលខុសត្រូវរៀបចំបញ្ជីនិងសំណុំលិខិតនានាទុកដាក់តាមប្រភេទ(កម្រងលិខិតចេញ-ចូល)។
- ធ្វើតារាងរាយនាមបុគ្គលិកអប់រំតាមតួនាទី ភារកិច្ច អតីតភាពការងារព្រមទាំងរៀបចំសំណុំលិខិតរបស់បុគ្គលិកអប់រំម្នាក់ៗឱ្យបានត្រឹមត្រូវ
- ណែនាំគ្រូបង្រៀនតាមកម្រិតថ្នាក់ឱ្យធ្វើប្រវត្តិរូបសង្ខេបនិងចុះអត្តលេខរបស់សិស្សក្នុងបញ្ជីហៅឈ្មោះ
- ណែនាំគ្រូឱ្យប្រើប្រាស់បញ្ជីហៅឈ្មោះសិស្សនិងបញ្ជីពិន្ទុសិស្សបឋមសិក្សាឬមត្តេយ្យសិក្សាឱ្យបានត្រឹមត្រូវដោយចុះចំនួនអវត្តមានសិស្សពិតប្រាកដទៅតាមថ្ងៃសិក្សាក្នុងខែនីមួយៗ ។
- រៀបចំស្ថិតិសិស្សឱ្យបានត្រឹមត្រូវ និងប្រភេទសិស្សដូចជា(ពិការ ក្រីក្រ កំព្រា ជួបការលំបាក...)
- រៀបចំតារាងតាមដានលទ្ធផលសិក្សារបស់សិស្សប្រចាំខែលើសមត្ថភាពអាន សរសេរដើម្បីជំរុញនិងជួយសិស្សទាន់ពេលសម្រាប់ថ្នាក់ទី១ ទី២ ទី៣
- រៀបចំសៀវភៅវេនតាមដានការរៀននិងបង្រៀនរបស់គ្រូ-សិស្សហើយត្រូវបូកសរុបជារៀងរាល់ថ្ងៃសិក្សា
- រៀបចំតារាងតាមដានលទ្ធផលសិក្សារបស់សិស្សតាមកម្រិតថ្នាក់ក្នុងខែនីមួយៗដោយ អនុវត្តគោលការណ៍ជួយសិស្សរៀនយឺតស្របពេលសិក្សាចាប់តាំងពីដើមឆ្នាំសិក្សារហូតដល់ចុងឆ្នាំសិក្សា។

## ២.ការបង្រៀននិងរៀនថ្ងៃព្រហស្បតិ៍ និងការប្រជុំបច្ចេកទេស

### ២.១-សម្រាប់បឋមសិក្សា

២.១.១ ការបង្រៀន និងរៀនថ្ងៃព្រហស្បតិ៍

សាលារៀនត្រូវអនុវត្តការបង្រៀនថ្ងៃព្រហស្បតិ៍ចំនួន២១ពេល(ព្រឹកឬរសៀល)រាល់សប្តាហ៍ទី១ ទី២ និងទី៣ ក្នុងខែ មករា កុម្ភៈ មីនា ឧសភា មិថុនា កក្កដា សីហា ឆ្នាំ២០១៧ ។ ការបង្រៀននៅថ្ងៃព្រហស្បតិ៍ជាសកម្មភាពរៀនសូត្រមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា អប់រំសិល្បៈ បំណិនជីវិត និងភាសាអង់គ្លេសសម្រាប់ថ្នាក់ទី៤-ទី៥-ទី៦ អនុវត្តម៉ោងក្នុងកម្មវិធីសៀវភៅសិក្សា តាមកម្រិតថ្នាក់ (តាមស្មារតីលិខិតលេខ៥២៦អយក.សណន ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៦ របស់ក្រសួងអប់រំ យុវជន និងកីឡា)។

២.១.២ ការប្រជុំក្រុមបច្ចេកទេស

ក្នុងមួយឆ្នាំសិក្សាត្រូវប្រជុំនៅតាមសាលារៀនផ្ទាល់ឬនៅតាមកម្រងសាលារៀនដោយកំណត់យកសប្តាហ៍ទី៤ រៀងរាល់ខែដើម្បីប្រជុំក្រុមបច្ចេកទេសដោយឡែកការឧបត្ថម្ភថវិកាត្រូវគិត ៧ពេលគឺ ខែ មករា កុម្ភៈ មីនា ឧសភា មិថុនា កក្កដា សីហា ឆ្នាំ២០១៧។

ការប្រជុំបច្ចេកទេសថ្ងៃព្រហស្បតិ៍មិនមែនផ្តោតតែលើការបូកសរុបលទ្ធផលនៃការបង្រៀននិងរៀននៅថ្ងៃព្រហស្បតិ៍នោះទេប៉ុន្តែសង្កត់ធ្ងន់លើវិធីសាស្ត្រនៃការបង្រៀនកិច្ចតែងការនិងផលិតសម្ភារឧបទេស ការធ្វើថ្នាក់និទស្សន៍និងការផ្លាស់ប្តូរបទពិសោធនៃការជួយសិស្សរៀនយឺតស្របពេលសិក្សា (តាមមុខវិជ្ជារងនីមួយៗក្នុងនិងក្រៅថ្នាក់)ឱ្យបានត្រឹមត្រូវ។ រាល់ការប្រជុំត្រូវមានរបៀបវារៈប្រធានបទ និងខ្លឹមសារច្បាស់លាស់ ដោយឆ្លុះបញ្ចាំងពីបញ្ហាពាក់ព័ន្ធនានា ការងារដែលសម្រេចបាននាខែកន្លងមក និងទិសដៅដែលត្រូវអនុវត្តក្នុងខែបន្ទាប់សម្រាប់កម្រិតថ្នាក់នីមួយៗ ។

### ២.២-សម្រាប់មត្តេយ្យសិក្សា

ក្នុងមួយឆ្នាំសិក្សា ត្រូវអនុវត្តការប្រជុំបច្ចេកទេសចំនួន ៣៨ពេលរៀងរាល់សប្តាហ៍ទាំងសាលាមត្តេយ្យសិក្សាដាច់ដោយឡែក និងសាលា/ថ្នាក់មត្តេយ្យនៅក្នុងសាលាបឋមសិក្សា។ ដោយឡែកការឧបត្ថម្ភថវិកាក្នុងការប្រជុំនេះមានចំនួនតែ១៤ពេលតែប៉ុណ្ណោះ។ ចំពោះសាលា/ថ្នាក់មត្តេយ្យសិក្សានៅជាមួយសាលាបឋមសិក្សាត្រូវប្រជុំជាមួយកម្រងសាលារៀន និងប្រជុំជាមួយសាលារៀនផ្ទាល់របស់ខ្លួនតាមផែនការកំណត់។ ការប្រជុំបច្ចេកទេស ប្រចាំសប្តាហ៍ផ្តោតលើវិធីសាស្ត្របង្រៀន និងរៀន សំដៅឱ្យការសិក្សារបស់កុមារសម្រេចបានលទ្ធផលជាវិជ្ជមាន ការប្រជុំបច្ចេកទេសអាចបែងចែកជា ៖

ការផលិតសម្ភារឧបទេស ការធ្វើថ្នាក់និទស្សន៍ ការពិភាក្សាលើកិច្ចតែងការបង្រៀន និងកម្មវិធីសិក្សាជាដើម។ រាល់ការប្រជុំត្រូវមានប្រធានបទខ្លឹមសារច្បាស់លាស់តាមការណែនាំដោយឆ្លុះបញ្ចាំងអំពីបញ្ហាពាក់ព័ន្ធនានា និងទិសដៅដែលត្រូវអនុវត្តក្នុងខែបន្ទាប់តាមកម្រិតថ្នាក់នីមួយៗ ។

## ៣.ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស

### ៣.១.សម្រាប់បឋមសិក្សា

៣.១.១.ការយកពិន្ទុប្រចាំខែ ត្រូវអនុវត្តចាប់ពីដើមខែ ធ្នូឆ្នាំ២០១៦ រហូតដល់ដំណាច់ខែ សីហា ឆ្នាំ២០១៧ លើកលែងតែថ្នាក់ទី១ ដែលត្រូវអនុវត្តចាប់ពីខែមករាឆ្នាំ២០១៧។ ក្នុងការវាយតម្លៃត្រូវអនុវត្តតាមខ្លឹមសារណែនាំក្នុងបញ្ជីពិន្ទុថ្មីដែលមានរាយមុខវិជ្ជារង ក្នុងមួយខែសិស្សម្នាក់ៗ ត្រូវមានពិន្ទុឱ្យបានគ្រប់ចំនួនតាមមុខវិជ្ជារង។ ដោយឡែក ពិន្ទុខែមេសា និងខែឧសភា ត្រូវបូកសរុបធ្វើចំណាត់ថ្នាក់ជាមួយគ្នា។

បញ្ជាក់ ៖ លទ្ធផលសិក្សាខែធ្នូ ឆ្នាំ២០១៦ និង ខែមករា កុម្ភៈ មីនាឆ្នាំ២០១៧ ត្រូវបញ្ចូលក្នុងឆមាសទី១ ក្រៅពីនេះត្រូវបញ្ចូលក្នុងឆមាសទី២។ ចំពោះថ្នាក់ទី១លទ្ធផលសិក្សាសម្រាប់ឆមាសទី១ ត្រូវយកលទ្ធផលសរុបនៃខែ មករា កុម្ភៈ មិនា ជាមូលដ្ឋាន។ រីឯឆមាសទី២ ត្រូវអនុវត្តដូចថ្នាក់ទី២ ដល់ទី៦ ដែរ។

៣.១.២-ការប្រឡងឆមាស

អនុវត្តតាមខ្លឹមសារណែនាំនៅក្នុងបញ្ជីពិន្ទុ ត្រូវធ្វើពីរដងក្នុងមួយឆ្នាំសិក្សា

- ឆមាសទី១ ៖ ចាប់ផ្ដើមពីដើមខែមករា ដល់ដំណាច់ ខែមីនា ឆ្នាំ២០១៧
- ឆមាសទី២៖ ចាប់ផ្ដើមពីដើមខែមេសា ឧសភា ដល់ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៧ ។

៣.១.៣-ការប្រជុំបូកសរុបលទ្ធផលសិក្សា

ការប្រជុំបូកសរុបលទ្ធផលសិក្សា នៅតាមសាលារៀនទាំងបឋមសិក្សានិងមត្តេយ្យសិក្សា ត្រូវអនុវត្តពីរដងក្នុងមួយឆ្នាំសិក្សា តាមកាលបរិច្ឆេទដូចខាងក្រោម ៖

- ឆមាសទី១៖ ចំនួន២ថ្ងៃគឺ ពីថ្ងៃទី០៤ ដល់ថ្ងៃទី ០៥ ខែមេសា ឆ្នាំ២០១៧
- ឆមាសទី២៖ ចំនួន២ថ្ងៃគឺ ពីថ្ងៃទី១៧ ដល់ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៧

៣.១.៤-ការធ្វើតេស្តឡើងថ្នាក់

គ្រប់គ្រឹះស្ថានបឋមសិក្សាសាធារណៈទាំងអស់ត្រូវ ៖

- ធ្វើតេស្តឡើងថ្នាក់នៅចុងឆ្នាំសិក្សា (ខែសីហា នៅចុងឆ្នាំ២០១៧) សម្រាប់សិស្សគ្រប់កម្រិតថ្នាក់ដែលធ្លាក់មធ្យមភាគប្រចាំឆ្នាំនិងសិស្សដែលគ្មានចំណាត់ថ្នាក់ ។
- រៀបចំធ្វើតេស្តដើមឆ្នាំសិក្សាថ្មី ២០១៦-២០១៧ ឡើងវិញចំពោះសិស្សដែលធ្លាក់តេស្តនៅចុងឆ្នាំសិក្សា២០១៥-២០១៦ក្នុងរយៈពេលយ៉ាងយូរ១សប្ដាហ៍ក្រោយថ្ងៃបើកបវេសនកាល។
  សាលារៀនត្រូវរៀបចំខ្លឹមសារតេស្តទាំងចុងឆ្នាំនិងដើមឆ្នាំសិក្សា។ សំគាល់៖ ចំពោះសិស្សរៀនត្រួតថ្នាក់ចាប់ពីពីរឆ្នាំឡើងទៅសាលារៀនត្រូវផ្ដល់ឱកាសឱ្យពួកគេបានឡើងថ្នាក់ទៅរៀននៅថ្នាក់បន្ទាប់ដោយស្វ័យប្រវត្តិ ក្នុងឆ្នាំសិក្សាទី៣(បី)។
- ធ្វើតេស្តស្ដង់ដាសម្រាប់សិស្សថ្នាក់ទី៣ ទី៦ នៅចុងឆ្នាំសិក្សាតាមកាលកំណត់របស់ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ ។
- រៀបចំវិញ្ញាសា និងកិច្ចការធ្វើតេស្តចុងឆ្នាំ ដើមឆ្នាំសិក្សា តេស្តស្ដង់ដា ថ្នាក់ទី៣ ទី៦ត្រូវរក្សាទុកនៅទីចាត់ការសាលារៀនផ្ទាល់ ។

### ៣.២-សម្រាប់មត្តេយ្យសិក្សា

ការវាយតម្លៃលទ្ធផលការសិក្សារបស់កុមារមត្តេយ្យសិក្សា គប្បីផ្អែកលើប្រការដែលកុមារត្រូវអនុវត្ត ដែលមានចែងក្នុងផ្នែកខាងក្រោយនៃបញ្ជីហៅឈ្មោះកុមារ សម្រាប់មតេយ្យសិក្សា និងតេស្តវាស់សមត្ថភាពកុមារៈ

៣.២.១-ការវាយតម្លៃលទ្ធផលសិក្សាប្រចាំថ្ងៃធ្វើឡើង ជារៀងរាល់ថ្ងៃនៅចុងម៉ោងសិក្សាដោយ ពាក្យសំដី កាយវិការ និងសម្ភារៈទៅតាមលទ្ធភាពរបស់គ្រូដើម្បីឱ្យកុមារដឹងពីចំណុចល្អ ចំណុចខ្វះខាតដែលត្រូវកែលម្អ (កុមារអនុវត្តបានល្អត្រូវទទួលបានទង់កុមារសុភាព) ។

៣.២.២-ការវាយតម្លៃលទ្ធផលសិក្សាប្រចាំសប្តាហ៍ ធ្វើនៅរៀងរាល់ចុងសប្តាហ៍ ដោយបូកសរុបលទ្ធផលរយៈពេល៥ថ្ងៃកន្លងមក (កុមារអនុវត្តបានល្អត្រូវទទួលបានប័ណ្ណកុមារសុភាព)។

៣.២.៣-ការវាយតម្លៃលទ្ធផលសិក្សាប្រចាំខែធ្វើឡើងរៀងរាល់ចុងសប្តាហ៍ទី៤ដោយបូកសរុបលទ្ធផលរយៈពេល៤សប្តាហ៍កន្លងមក(កុមារអនុវត្តបានល្អត្រូវទទួលបានប័ណ្ណកុមារឈ្លាសវៃ)។

៣.២.៤-ការវាយតម្លៃលទ្ធផលសិក្សាប្រចាំត្រីមាសធ្វើឡើងជារៀងរាល់ត្រីមាស(ចុងត្រីមាស)ដោយធ្វើការបូកសរុបលទ្ធផលរយៈពេល៣ខែកន្លងមក (កុមារអនុវត្តបានល្អត្រូវទទួលបានប័ណ្ណបុប្ផាក្រហម)។

៣.២.៥-ការវាយតម្លៃសមត្ថភាពកុមារ កុមារត្រូវអនុវត្តនូវតេស្តទៀងទាត់ ៣ដង ក្នុងមួយឆ្នាំសិក្សាសម្រាប់កុមារអាយុ ៥ ឆ្នាំ លើកទី១ នៅសប្តាហ៍ទី ១ ខែវិច្ឆិកា លើកទី ២ សប្តាហ៍ទី ១ ខែកុម្ភៈ និងលើកទី ៣ សប្តាហ៍ទី ៣ ខែកក្កដា។

## ៤.ការងារពិនិត្យតាមដាន វាយតម្លៃ

មន្ទីរអប់រំ យុវជន និងកីឡា រាជធានីខេត្ត ត្រូវរៀបចំផែនការពិនិត្យតាមដាន និងវាយតម្លៃមួយច្បាស់លាស់ ដោយចាត់តាំងក្រុមបំប៉ន និងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌ (DTMTs) ឱ្យទទួលខុសត្រូវចុះជួយដល់នាយកសាលារៀននិងគ្រូបង្រៀននៅតាមមូលដ្ឋានដែលបានកំណត់របស់រាជធានីខេត្តសាមី។ រាល់ការពិនិត្យតាមដានត្រូវអនុវត្តតាមគោលការណ៍ណែនាំ កម្រងតួនាទី និងភារកិច្ច របស់ក្រុមបំប៉ន និងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលទើបបានកែសម្រួលថ្មីនិងដាក់ឱ្យអនុវត្ត។ នៅក្នុងឆ្នាំសិក្សា២០១៦-២០១៧នេះសាលារៀននីមួយៗ ត្រូវធ្វើស្វ័យវង្វាយតម្លៃឱ្យបាន២ដងក្នុង១ឆ្នាំសិក្សា(ដំណាច់ឆមាសទី១និងដំណាច់ឆមាសទី២)ឯគ្រូបង្រៀនម្នាក់ៗក៏ត្រូវធ្វើស្វ័យវាយតម្លៃការងារថ្នាក់រៀនឱ្យបានទៀងទាត់ជារៀងរាល់ខែដោយប្រើប្រាស់ឧបករណ៍វាយតម្លៃរបស់សាលាកុមារមេត្រី។ រាល់ការវាយតម្លៃត្រូវប្រើប្រាស់បញ្ជីពិនិត្យតាមដាននិង វាយតម្លៃលទ្ធផលការងាររបស់សាលារៀនក្នុងកម្មវិធីសាលាកុមារមេត្រីដើម្បីធ្វើការពិនិត្យតាមដាននិងវាយតម្លៃព្រមទាំងធ្វើចំណាត់ថ្នាក់សាលាកុមារមេត្រីទៅតាមកម្រិតទាំងបី(មូលដ្ឋាន មធ្យម និង អភិវឌ្ឍ) ដោយអនុវត្តតាមលិខិតលេខ ៥៨០២អយក-បស ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការដាក់ឱ្យអនុវត្តកម្រងតួនាទី ភារកិច្ចរបស់ក្រុមបំប៉ន និងពិនិត្យតាមដានថ្នាក់ ក្រុង ស្រុក ខណ្ឌ និងគោលការណ៍កំណត់សាលាកុមារមេត្រីតាមកម្រិត ។

ចំពោះមត្តេយ្យសិក្សា អ្នកទទួលបន្ទុកអប់រំកុមារតូច ក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត ត្រូវចុះពិនិត្យតាមដានការងារ២ដងក្នុងមួយឆ្នាំយ៉ាងតិច ។ នាយក នាយិកាសាលារៀន គណៈកម្មការទទួលបន្ទុកកិច្ចការនារី និងកុមារត្រូវចុះពិនិត្យតាមដានជាប្រចាំ ដោយប្រើប្រាស់ឧបករណ៍ដែលកំណត់ដោយនាយកដ្ឋានអប់រំកុមារតូច នៃក្រសួងអប់រំ យុវជន និងកីឡា ។

## ៥-ការរៀបចំនិងបញ្ជូនរបាយការណ៍

របាយការណ៍សាលារៀនត្រូវរៀបចំឱ្យត្រូវទៅតាមនាយកដ្ឋានជំនាញនីមួយៗនិងតាមដំណាក់កាលដូចខាងក្រោម ៖

៥.១ - របាយការណ៍ឆមាសទី១៖ មានគំរូរបស់នាយកដ្ឋានបឋមសិក្សា និងនាយកដ្ឋានអប់រំកុមាតូច

- ពីថ្ងៃទី២៥ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៧ គ្រប់សាលារៀនត្រូវបញ្ជូនរបាយការណ៍មកកម្រងសាលារៀន ។
- ពីថ្ងៃទី០១ដល់ថ្ងៃទី០៦ ខែឧសភា ឆ្នាំ ២០១៧ គ្រប់កម្រងសាលាត្រូវបញ្ជូនរបាយការណ៍មកការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ។
- ពីថ្ងៃទី០៨ ដល់ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១៧ គ្រប់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនរបាយការណ៍មកមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ។

**បញ្ជាក់ ៖** គ្រប់មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត មិនបាច់ផ្ញើរបាយការណ៍បវេសនកាលមកនាយកដ្ឋានបឋមសិក្សាទេ ប៉ុន្តែត្រូវបញ្ជូនរបាយការណ៍លទ្ធផលតេស្តឡើងថ្នាក់ចុងឆ្នាំសិក្សា មកនាយកដ្ឋានបឋមសិក្សាឱ្យបានមុនថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៧ និងតេស្តដើមឆ្នាំសិក្សា ឱ្យបានត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០១៧ ។

៥.២-របាយការណ៍ឆមាសទី ២ និងដំណាច់ឆ្នាំ (គំរូរបស់នាយកដ្ឋានបឋមសិក្សា និងនាយកដ្ឋានអប់រំកុមារតូច)។

- ពីថ្ងៃទី២៨ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៧ សាលារៀន បញ្ជូនរបាយការណ៍មកកម្រងសាលារៀន
- ពីថ្ងៃទី០៤ដល់ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៧ កម្រងសាលារៀន បញ្ជូនរបាយការណ៍មកការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ។
- ពីថ្ងៃទី១១ដល់ថ្ងៃទី១៤ ខែកញ្ញាឆ្នាំ២០១៧ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ បញ្ជូនរបាយការណ៍មកមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ។
- ពីថ្ងៃទី១៨ ដល់ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៧ មន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្ត បញ្ជូនរបាយការណ៍មក នាយកដ្ឋានបឋមសិក្សាមួយច្បាប់ និងនាយកដ្ឋានអប់រំ កុមារតូចមួយច្បាប់។
- ចំពោះតួលេខស្ថិតិគ្រប់ របាយការណ៍ត្រូវដូចគ្នាជាមួយនឹងស្ថិតិរបស់ការិយាល័យផែនការ នៃមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត និងរៀបចំទៅតាម គំរូ ជូនភ្ជាប់របស់នាយកដ្ឋាន រួចបញ្ជូនតាមឋានានុក្រមអប់រំ ជាបន្តបន្ទាប់ឱ្យបានមុនកាលកំណត់យ៉ាងយូរមួយសប្តាហ៍។

- ត្រូវបញ្ចូលលទ្ធផលតេស្តឡើងថ្នាក់ ចុងឆ្នាំនិងដើមឆ្នាំសិក្សា និងតេស្តស្តង់ដារ (សម្រាប់សិស្ស ថ្នាក់ទី៣ និងទី៦ ) ទៅក្នុងរបាយការណ៍ដំណាច់ឆ្នាំ។

### ៦.ការធានាបរិមាណក្នុងការអនុវត្តកម្មវិធីសិក្សា

៦.១.នៅក្នុងដំណើរការនៃឆ្នាំសិក្សាៈ នាយក នាយិកាសាលាមិនមានសិទ្ធិបិទសាលារៀន ដោយគ្មានការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡានោះទេ ទោះបីក្នុងប្រការណាក៏ដោយ ។

៦.២.ក្នុងករណីប្រធានសក្តិ (ទឹកជំនន់ ខ្យល់ព្យុះ...) នាយក នាយិកាសាលារៀនត្រូវធ្វើរបាយការណ៍បន្ទាន់ជូនក្រសួងអប់រំ យុវជន និងកីឡាដោយមានការឯកភាពពីការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ មន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្ត ដើម្បីសុំការអនុញ្ញាត ផ្អាកដំណើរការសិក្សាជាបណ្តោះអាសន្នតាមសេចក្តីណែនាំ លេខ ២៧ អយក.សណន.ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១២ ស្តីពីការអប់រំក្នុងកម្មវិធីសង្គ្រោះបន្ទាន់ដោយផ្តោតលើការរៀបចំទីកន្លែងថ្នាក់រៀនមានសុវត្ថិភាពក្នុងពេលមាន ទឹកជំនន់ ។

៦.៣.គ្រប់សាលារៀនត្រូវពង្រឹងការអនុវត្តកាលវិភាគ វិមជ្ឈការកាលវិភាគនិងប្រតិទិនសិក្សាឱ្យបានត្រឹមត្រូវចៀសវាងបាតុភាពឈប់ ឬបិទសាលារៀនមុនពេលកំណត់និងចូលរៀនក្រោយពេលកំណត់ ដោយអនុវត្តតាមស្មារតី នៃសេចក្តីណែនាំលេខ ២១៣៨ អយក.សណន.ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការអនុវត្តប្រតិទិនសិក្សានៅតាមសាលារៀនចំណេះ ទូទៅសាធារណៈ និងសេចក្តីណែ នាំលេខ ២១ អយក.សណន ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១០ ស្តីពីការអនុវត្តបទបញ្ជាផ្ទៃក្នុងសម្រាប់គ្រឹះស្ថានបឋមសិក្សាសាធារណៈ និងប្រកាសលេខ ២៤៩១ អយក.ប្រក.ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ស្តីពីបទបញ្ជាផ្ទៃក្នុង សម្រាប់គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ។

៦.៤.គ្រប់សាលាមត្តេយ្យសិក្សា និងថ្នាក់មត្តេយ្យសិក្សាទាំងអស់ត្រូវបិទផ្សាយសកម្មភាពអនុវត្តជាមួយកុមារប្រចាំថ្ងៃលើក្តារខៀន ឬបញ្ជរព័ត៌មានតាមថ្នាក់នីមួយៗ។

## IV-ភារកិច្ចក្នុងពេលវិស្សមកាល

### ១.ភារកិច្ចបុគ្គលិកអប់រំ

នៅក្នុងរយៈពេលវិស្សមកាលតូច និងមហាវិស្សមកាលសាលារៀននីមួយៗត្រូវចាត់តាំងការយាមកាមជាប្រចាំ (យប់ និងថ្ងៃ) ដើម្បីការពារសុវត្ថិភាពសាលារៀនឱ្យបានល្អ ចៀសវាងនូវការបាត់បង់ ឬខូចខាតទ្រព្យសម្បត្តិរបស់សាលារៀន។ នាយក នាយិកាសាលារៀននីមួយៗ ត្រូវរៀបចំសមាសភាពបែងចែកវេនយាមទៅតាមលទ្ធភាពដោយមានការចូលរួមពីគណៈនាយក គ្រូបង្រៀន និងសិស្ស ឬសហគមន៍ត្រូវចូលរួមការងារតាមការចាត់តាំងរបស់គណៈនាយកតាមឋានានុក្រមអប់រំដោយធ្វើការត្រួតពិនិត្យឱ្យបានទៀងទាត់រាល់សប្តាហ៍។គ្រប់ក្រុមយាមត្រូវមានចុះវត្តមាន និងធ្វើកំណត់ហេតុច្បាស់លាស់ក្នុងករណីណាដែលមានឧបទ្ទវហេតុកើតឡើង ។

### ២.ការអបអរដំណាច់ឆ្នាំ

គ្រប់គ្រឹះស្ថានបឋមសិក្សាសាធារណៈត្រូវរៀបចំពិធីអបអរសាទរ ដំណាច់ឆ្នាំសិក្សាតាមទ្រង់ទ្រាយ តូច មធ្យម ធំ ដែលអាចមានការចូលរួមពីក្រសួង មន្ទីរ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ មាតាបិតាអ្នកអាណាព្យាបាលសិស្ស អាជ្ញាធរដែនដី ដោយមានការកៀរគរ និងចលនារក អំណោយដើម្បីផ្តល់ជូន និងលើកទឹកចិត្តសិស្ស ។ កម្មវិធីអាចប្រព្រឹត្តទៅនៅចុង ខែកញ្ញាឬដើមខែ តុលា នៃឆ្នាំសិក្សា ដោយអនុវត្តតាមកម្មវិធីដូចខាងក្រោម ៖

- របាយការណ៍នាយក នាយិកាសាលា
- ចំណាប់អារម្មណ៍សិស្សប្អូន និងការផ្តាំផ្ញើរបស់សិស្សច្បង ( ថ្នាក់ទី៦ )
- មតិសំណេះសំណាលរបស់គណៈអធិបតី
- ពិធីចែករង្វាន់ និងការលើកទឹកចិត្តសិស្ស

ទទួលសេចក្តីណែនាំនេះ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់គ្រប់ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ កម្រងសាលារៀន និងសាលារៀន និងចាត់តាំងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែតុលា ឆ្នាំ ២០១៦

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិត ហង់ ជួន ណារ៉ុន**

កន្លែងទទួល
-គ្រប់សាលារាជធានី ខេត្ត
-ខុទ្ទកា ល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
-អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា
-ដៃគូអភិវឌ្ឍដែលពាក់ព័ន្ធ
" ដើម្បីជ្រាបជាព័ត៌មាន "
-គ្រប់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
" ដើម្បីអនុវត្ត "
-កាលប្បវត្តិ- ឯកសារ នាប.ស